**<u>សេចក្តីថ្លែងការណ៍បញ្ចប់បេសកកម្ម</u>**

<u>ដោយអ្នករាយការណ៍ពិសេសស្តីពីសិទ្ធិមនុស្សនៅកម្ពុជា</u>

<u>អ្នកស្រី សាស្ត្រាចារ្យ រ៉ូណា ស្មីត</u>

ភ្នំពេញ ១៤ មីនា ២០១៨

**ពិនិត្យផ្ទៀងផ្ទាត់នឹងសេចក្តីថ្លែងផ្ទាល់មាត់**

នៅពេលនេះ ខ្ញុំបានបញ្ចប់ដំណើរទស្សនកិច្ចលើកទីប្រាំរបស់ខ្ញុំមកកាន់ព្រះរាជាណាចក្រកម្ពុជា ក្នុងនាមខ្ញុំជាអ្នករាយការណ៍ពិសេស អ.ស.ប ស្តីពីស្ថានភាពសិទ្ធិមនុស្សនៅកម្ពុជា។ ខ្ញុំសូមថ្លែងអំណរគុណដល់រដ្ឋាភិបាលដែលបានអញ្ជើញខ្ញុំមកបំពេញទស្សនកិច្ច និងចំពោះឆន្ទៈរបស់មន្ត្រីជាច្រើនរបស់រដ្ឋ ក្នុងការជួបប្រជុំជាមួយខ្ញុំ និងពិភាក្សាដោយចំហអំពីសិទ្ធិមនុស្សនៅកម្ពុជា។ ខ្ញុំសូមសំដែងការកោតសរសើរផងដែរ ចំពោះការលះបង់ និងការខិតខំប្រឹងប្រែងរបស់បុគ្គលិកទាំងអស់នៃការិយាល័យឧត្តមស្នងការអង្គការសហប្រជាជាតិ (OHCHR) ប្រចាំកម្ពុជា និងនៅទីក្រុងហ្សឺណែវ ដែលបានរៀបចំនិងគាំទ្រប្រកបដោយសមត្ថភាព ដល់ដំណើរបេសកកម្មនេះ។

នៅក្នុងអំឡុងពេលបំពេញបេសកកម្មនេះ ខ្ញុំបានមានបុព្វសិទ្ធិជួបប្រជុំជាមួយមន្ត្រីជាន់ខ្ពស់មួយចំនួន ជាពិសេសសម្តេចអគ្គមហាពញាចក្រី ហេង សំរិន (ប្រធានរដ្ឋសភា), សម្តេចក្រឡាហោម ស ខេង (ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ), ឯកឧត្តម ប្រាក់ សុខុន (ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ), ឯកឧត្តម អូន ព័ន្ធមុន្នីរ័ត្ន (ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ), ឯកឧត្តម អង្គ វង្សវឌ្ឍានា (រដ្ឋមន្ត្រីក្រសួងយុត្តិធម៌), ឯកឧត្តម ម៉ម ប៊ុនហេង (រដ្ឋមន្ត្រីក្រសួងសុខាភិបាល), ឯកឧត្តម យូ ប៊ុនឡេង (ប្រធានសាលាឧទ្ធរណ៍), ឯកឧត្តម យូ ឧត្តរា (អនុប្រធានតុលាការកំពូល), ឯកឧត្តម កែវ រ៉េមី (ប្រធានគណៈកម្មាធិការសិទ្ធិមនុស្សកម្ពុជា), ឯកឧត្តម ស៊ិក ប៊ុនហុក (ប្រធានគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត) ហើយនិង ឯកឧត្តម សែម សុខា (រដ្ឋលេខាធិការក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា)។ ខ្ញុំបានជួបប្រជុំផងដែរជាមួយអ្នកពាក់ព័ន្ធដទៃទៀត រាប់បញ្ចូលទាំងអ្នកតំណាងសង្គមស៊ីវិល គណបក្សនយោបាយផ្សេងៗ សហគមន៍ការទូត ក្រុមអង្គការសហប្រជាជាតិប្រចាំប្រទេស និងអ្នកដទៃទៀត។ ខ្ញុំសូមថ្លែងអំណរគុណផងដែរ ចំពោះអ្នកទាំងអស់ដែលបានឆ្លៀតពេលវេលា ដើម្បីធ្វើការចែករំលែកការយល់ឃើញ និងព័ត៌មានផ្សេងៗជាមួយខ្ញុំ។ ខ្ញុំត្រូវបានបដិសេធជាថ្មីម្តងទៀតនូវសិទ្ធិជួបជាមួយជនជាប់ឃុំ ដែលនៅក្នុងឱកាសនេះ មានឯកឧត្តម កឹម សុខា នៅមណ្ឌលអប់រំកែប្រែទី៣ ទោះជាយ៉ាងនេះក៏ដោយ ក៏ខ្ញុំត្រូវបានផ្តល់ឱកាសឱ្យធ្វើទស្សនកិច្ចទៅកាន់ពន្ធនាគារប៉េស៊ី(PJ) និងជួបជាមួយលោក ញឹក ប៊ុនឆៃ។

ខ្ញុំមានសេចក្តីរីករាយ សូមធ្វើសេចក្តីរាយការណ៍អំពីរបកគំហើញបឋមនៃដំណើរទស្សនកិច្ចរបស់ខ្ញុំ។ ខ្ញុំនឹងបង្ហាញរបាយការណ៍ចុងក្រោយនេះ នាសម័យប្រជុំរបស់ក្រុមប្រឹក្សាសិទ្ធិមនុស្ស នៅខែកញ្ញា នាទីក្រុងហ្សឺណែវ។

ប្រទេសកម្ពុជានៅតែបន្តទទួលបានកំណើនសេដ្ឋកិច្ចដ៏រឹងមាំ និងការអភិវឌ្ឍយ៉ាងឆាប់រហ័ស ដែលបានផ្តល់ធនធានសម្រាប់ការលើកកម្ពស់កិច្ចការពារសង្គម និងការទទួលបានការអប់រំ ការងារ និងកិច្ចគាំពារសុខភាពសមរម្យ។ ខ្ញុំមានសេចក្តីរីករាយចំពោះផែនការអភិវឌ្ឍសន្តិសុខសង្គម និងមូលនិធិសមធម៌សុខភាព និងធ្វើការឈានទៅរកលទ្ធភាពទទួលបានកិច្ចគាំពារសុខភាពជាសកល។ ខ្ញុំរីករាយផងដែរ ចំពោះគម្រោងសាកល្បងស្តីពីការផ្ទេរមូលនិធិដល់ស្រ្តីមានផ្ទៃពោះ និងស្រ្តីដែលទើបនឹងសម្រាលកូន។ ការបង់ថ្លៃសេវាមាតុភាពសម្រាប់ស្រ្តីនៅក្នុងវិស័យវាយនភ័ណ្ឌ (ប្រាក់ខែ ១២០% សម្រាប់រយៈពេលបីខែ) ក៏ជាចំណុចវិជ្ជមានផងដែរ។ កិច្ចគាំពារសុខភាព និងសន្តិសុខសង្គមមានតម្លៃខ្ពស់ ប៉ុន្តែជានិច្ចកាល ការណ៍នេះត្រូវបានរដ្ឋាភិបាលបណ្តាក់ទុនដ៏មានតម្លៃសម្រាប់ប្រជាជនរបស់ខ្លួន។ រាល់គម្រោងផែនការ និងយុទ្ធសាស្រ្តទាំងអស់នេះ សុទ្ធតែត្រូវការឲ្យមានធនធានគ្រប់គ្រាន់ និងមានការឃ្លាំមើលយ៉ាងដិតដល់រឹងមាំ។ ទាំងនៅក្នុងប្រទេសកម្ពុជា ទាំងនៅលើពិភពលោក ស្រ្តីមានផ្ទៃពោះបានបន្តបាត់បង់ការងាររបស់ខ្លួនដោយសារមូលហេតុមិនត្រឹមត្រូវ នៅពេលដែលផ្ទៃពោះអាចមើលឃើញច្បាស់ ឬត្រូវបានគេជូនដំណឹង។ ហេតុផល "ជាផ្លូវការ" មានលក្ខណៈផ្សេងៗគ្នា ប៉ុន្តែនៅទីបំផុត ស្រ្តីត្រូវបាត់បង់ការងារ ហើយអត្ថប្រយោជន៍ពាក់ព័ន្ធដទៃផ្សេងទៀតរបស់ពួកគាត់ ក៏ត្រូវបាត់បង់ស្របពេលគ្នានោះដែរ ដែលធ្វើឲ្យពួកគាត់ និងកូនរបស់គាត់ងាយរងគ្រោះជាពិសេស។ នៅប្រទេសកម្ពុជា នៅតែបន្តមានមនុស្សដែលជួបបញ្ហាមិនអាចទទួលបានសេវាគាំពារសុខភាពដោយឥតគិតថ្លៃ ទោះបីជាមានប័ណ្ណបេឡាជាតិរបបសន្តិសុខសង្គម (ប.ស.ស.) ហើយនិងប័ណ្ណមូលនិធិសមធម៌សុខភាពហើយក្តី។ **ខ្ញុំលើកទឹកចិត្តដល់រដ្ឋាភិបាលសូមឲ្យបន្តយកចិត្តទុកដាក់ក្នុងវិស័យសុខាភិបាល សន្តិសុខសង្គម និងការអប់រំ និងធ្វើការងារជាលក្ខណៈអន្តរក្រសួង និងជាមួយស្ថាប័នរដ្ឋាភិបាលនៅគ្រប់ថ្នាក់ ដើម្បីធានាថា សេវាកម្មទាំងនេះអាចរកបាន អាចមានលទ្ធភាពប្រើប្រាស់បាន  អាចទទួលយកបាន និងមានគុណភាពខ្ពស់ សម្រាប់ប្រជាជនកម្ពុជាគ្រប់រូប។**

ប្រទេសកម្ពុជាបានប្តេជ្ញាគាំទ្រដល់គ្រប់គោលដៅអភិវឌ្ឍន៍ដោយចីរភាព រួមបន្ថែមទាំងគោលដៅបោសសំអាតមីននិងគ្រាប់មិនទាន់ផ្ទុះផងដែរ។ ខណៈពេលដែលកម្ពុជានឹងបង្ហាញពីផែនការមូលដ្ឋានរូបនីយកម្មនៃគោលដៅទាំងនេះសម្រាប់អនុវត្តក្នុងប្រទេសរបស់ខ្លួនទៅកាន់ក្រុមការងារជាន់ខ្ពស់នាឆ្នាំក្រោយ ភ័ស្តុតាងនៃការវិវឌ្ឍន៍ជាក់ស្តែងសំដៅសម្រេចឱ្យបាននូវគោលដៅទាំងអស់ត្រូវបានចាត់ទុកជារឿងដ៏សំខាន់របស់កម្ពុជា។ ក្នុងករណីនេះ ការកៀរគរធនធាននានាគឺជាចំណុចគន្លឹះ។ នៅក្នុងជំនួបជាមួយរដ្ឋមន្រ្តីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ខ្ញុំបានពិភាក្សាអំពីតម្រូវការចាត់ថ្នាក់អាទិភាពទៅលើការវិនិយោគក្នុងវិស័យសិទ្ធិមនុស្ស និងក្នុងគោលដៅអភិវឌ្ឍន៍ដោយចីរភាពទាំងឡាយដែលពាក់ព័ន្ធវិស័យសិទ្ធិមនុស្ស។ ការផ្តល់ធនធានគ្រប់គ្រាន់សម្រាប់សកម្មភាពអភិវឌ្ឍន៍ និងការអនុវត្តសិទ្ធិមនុស្សគឺជាការចូលរួមចំណែកដល់ការកសាងសន្តិភាពនិងស្ថេរភាពរបស់សង្គម។ **ខ្ញុំទន្ទឹងរង់ចាំទទួលផែនការធ្វើមូលដ្ឋានរូបនីយកម្មនៃគោលដៅអភិវឌ្ឍន៍ដោយចីរភាព (ដែលខ្ញុំយល់ថានឹងអាចត្រូវផ្សព្វផ្សាយក្នុងឆ្នាំនេះ) និងមានឆន្ទៈធ្វើការងារជាមួយរដ្ឋាភិបាល និងដៃគូអភិវឌ្ឍន៍នានាដែលជ្រើសរើសដោយរដ្ឋាភិបាលសំដៅធ្វើយ៉ាងណាឱ្យកម្ពុជាសម្រេចឱ្យបាន និងសម្រេចលើសពីសូចនាករដែលបានកំណត់។**

ដើម្បីធ្វើឱ្យសមិទ្ធផលខាងសិទ្ធិសេដ្ឋកិច្ចនិងសិទ្ធិសង្គមមានការចាក់ឫសយ៉ាងរឹងមាំ វាគឺជារឿងដ៏ចាំបាច់ ដែលយើងត្រូវគោរពឱ្យបាននូវសិទ្ធិពលរដ្ឋនិងសិទ្ធិនយោបាយ។ ចាប់តាំងពីខ្ញុំបានរាយការណ៍ទៅកាន់ក្រុមប្រឹក្សាសិទ្ធិមនុស្សតាំងពីខែកញ្ញា ឆ្នាំ២០១៧ មក ការរឹតត្បិតផ្នែកសេរីភាពក្នុងការប្រមូលផ្តុំ សេរីភាពខាងការបញ្ចេញមតិ និងសេរីភាពខាងសមាគម រឹតតែកើនឡើងយ៉ាងធ្ងន់ធ្ងរ មិនតែប៉ុណ្ណោះការចូលរួមក្នុងសកម្មភាពនយោបាយ និងសិទ្ធិបោះឆ្នោតក៏មានការប្រែប្រួលយ៉ាងគំហុកផងដែរ។ ជាលទ្ធផល គួរអង្គនយោបាយត្រូវបានហាមឃាត់មិនឱ្យចូលរួមធ្វើសកម្មភាពនយោបាយជាតិ ប្រព័ន្ធផ្សព្វផ្សាយត្រូវបានបិទ ហើយគួរអង្គសង្គមស៊ីវិលជាច្រើនមានភាពស្ទាក់ស្ទើរក្នុងការនិយាយស្តីជាចំហ ឬក្នុងការធ្វើសកម្មភាពការពារសិទ្ធិមនុស្ស។

នៅឯកិច្ចប្រជុំក្រុមប្រឹក្សាសិទ្ធិមនុស្សក្នុងខែ កញ្ញា ឆ្នាំ២០១៧ (ពោលគឺក្រោយពេលមានការចាប់ខ្លួនលោក កឹម សុខា ដែលជាប្រធានអតីតគណបក្សសង្គ្រោះជាតិ) រដ្ឋជាច្រើនបានលើកឡើងអំពីកង្វល់នានាទាក់ទងនឹងធម្មានុរូបភាព និងភាពអាចជឿទុកចិត្តបានសម្រាប់ការបោះឆ្នោតនាពេលខាងមុខ។ ការរំលាយគណបក្សសង្គ្រោះជាតិនៅថ្ងៃទី១៦ ខែវិច្ឆិកា, ការហាមឃាត់សមាជិកទាំង ១១៨ រូប នៃគណបក្សសង្គ្រោះជាតិ មិនឱ្យធ្វើសកម្មភាពនយោបាយសម្រាប់រយៈពេលប្រាំឆ្នាំ ហើយនិងការបែងចែកអាសនៈទាំងអស់របស់គណបក្សនេះឡើងវិញ ទាំងនៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ ហើយចែកទៅឱ្យសមាជិកផ្សេងទៀតដែលប្រជាពលរដ្ឋមិនបានបោះឆ្នោតឱ្យ (ដែលសមាជិកទាំងនោះមកពីគណបក្សកាន់អំណាច និងគណបក្សផ្សេងៗ) គឺជាការបដិសេធសិទ្ធិជ្រើសរើសអ្នកតំណាងសម្រាប់កិច្ចការសាធារណៈតាមរយៈមធ្យោបាយជ្រើសរើសដោយសេរី ហើយដែលសិទ្ធិនោះត្រូវបានប្រើប្រាស់ដោយប្រជាជនដែលមានចំនួនច្រើនគួរឱ្យកត់សម្គាល់។ **ខ្ញុំអំពាវនាវឡើងវិញដល់រដ្ឋាភិបាលឱ្យស្តារលំហសម្រាប់ឱ្យប្រជាជនកម្ពុជាគ្រប់រូបអាចអនុវត្តសិទ្ធឈរឈ្មោះឱ្យគេបោះឆ្នោតឡើងវិញដោយគ្មានសេចក្តីភ័យខ្លាច ឬការបំភិតបំភ័យ។ ខ្ញុំក៏អំពាវនាវផងដែរឱ្យមានការពិចារណាឡើងវិញជាបន្ទាន់មួយទៅលើបម្រាមជាទូទៅហាមឃាត់តួអង្គនយោបាយទាំង ១១៨ រូបនោះ។**

លើសពីនេះទៅទៀត ខ្ញុំបានសម្តែងកង្វល់ដល់រដ្ឋាភិបាល ចំពោះការបន្តបិទលំហសង្គមស៊ីវិល និងការរឹតត្បិតទៅលើសិទ្ធិសេរីភាពជាមូលដ្ឋាននៅកម្ពុជា។ លក្ខខណ្ឌតម្រូវខាងនីតិវិធីគឺដើរហួសពីច្បាប់ ដែលបង្កើតឲ្យមានឧបសគ្គបន្ថែមទៀតដល់ការងារស្របច្បាប់របស់អង្គការសង្គមស៊ីវិលនានា។ បទប្បញ្ញត្តិផ្សេងៗដែលមានចែងក្នុងក្រមព្រហ្មទណ្ឌ ត្រូវបានប្រើប្រាស់ ដើម្បីរឹតត្បិតដល់សេរីភាពក្នុងការបញ្ចេញមតិកាន់តែកើនច្រើនឡើងជាលំដាប់។ បទប្បញ្ញត្តិថ្មីៗក្នុងក្រមព្រហ្មទណ្ឌ និងរដ្ឋធម្មនុញ្ញ បើកផ្លូវឲ្យមានការរឹតត្បិតលើសេរីភាពច្រើនថែមទៀត។ សេរីភាពទាំងនេះ អាចរឹតត្បិតទៅបាន តែក្នុងករណីមានមូលហេតុសមមាត្រកម្រិតតិចតួចប៉ុណ្ណោះ។ រដ្ឋាភិបាល និងតុលាការ ត្រូវប្រើប្រាស់ច្បាប់ជាសំអាងឲ្យមានលក្ខណៈស៊ីសង្វាក់គ្នា។

ខ្ញុំបានលើកអំពីករណីមួយចំនួនជាហូរហែរ ជាមួយរដ្ឋាភិបាល ដែលខ្ញុំយល់ថា ករណីទាំងនេះ អាចនឹងបង្កើតបរិយាកាសភ័យខ្លាច និងការបំភិតបំភ័យ ដែលអាចប៉ះពាល់ជាអវិជ្ជមានដល់សិទ្ធិសេរីភាពរបស់អ្នកដទៃ ក្នុងការបញ្ចេញមតិ ដែលនាំដល់ដាក់ការរឹតត្បិតការនិយាយស្តី និងការរារាំងដល់ការពិភាក្សាដេញដោលជាសាធារណៈ ប្រកបដោយការទទួលខុសត្រូវ និងភាពឆ្នៃប្រឌិត ស្តីពីបញ្ហាទាំងឡាយពាក់ព័ន្ធនឹងផលប្រយោជន៍សាធារណៈ។ ប្រការនេះ មានលក្ខណៈធ្ងន់ធ្ងរជាពិសេស ដោយសារតែការបោះឆ្នោតជាតិ នឹងត្រូវធ្វើឡើងនៅថ្ងៃទី២៩ ខែកក្កដា ឆ្នាំ២០១៨ ខាងមុខនេះ។ **ការរឹតត្បិតសម្លេងប្រជាពលរដ្ឋកម្ពុជា នៅទីបំផុតអាចជាការគំរាមកំហែងដល់ស្ថិរភាព ដែលរដ្ឋាភិបាល និងប្រជាពលរដ្ឋ បានធ្វើការយ៉ាងលំបាកដើម្បីកសាងវា។ សេរីភាពខាងសមាគម សេរីភាពក្នុងការបញ្ចេញមតិ និងសេរីភាពក្នុងការជួបប្រជុំដោយសន្តិវិធី ត្រូវបានការពារ និងត្រូវធ្វើឱ្យប្រសើរឡើង (ដោយមិនមែនត្រូវរឹតត្បិតឡើយ) នៅក្នុងសង្គមប្រជាធិបតេយ្យសេរីពហុបក្ស។**

ខ្ញុំបានបញ្ចេញទស្សនៈរបស់ខ្ញុំជាច្រើនដងមកហើយអំពីការបន្តមាននិន្នាការរបស់រដ្ឋាភិបាលចំពោះការគ្រប់គ្រងដោយយកច្បាប់ជាខែល (Rule by law) ជាជាងការអនុលោមតាមនីតិរដ្ឋ ដែលកំណត់ដោយរដ្ឋធម្មនុញ្ញ។

នីតិរដ្ឋ មានអត្ថន័យលើសពីការអនុវត្តច្បាប់។ វាមានន័យថា មិនមាននរណាម្នាក់ រួមទាំងរដ្ឋាភិបាលផងដែរ មិនអាចនៅពីលើច្បាប់បានទេ។ បុគ្គលគ្រប់រូប ហើយនិងស្ថាប័ន និងអង្គភាពទាំងឡាយ ត្រូវតែមានការទទួលខុសត្រូវចំពោះច្បាប់ទាំងឡាយដែលបានប្រកាសឲ្យប្រើប្រាស់ជាសាធារណៈ ច្បាប់ដែលមានការវិនិច្ឆ័យដោយឯករាជ្យ ដែលស្របទៅតាមបទដ្ឋានសិទ្ធិមនុស្សអន្តរជាតិ។ បើមិនដូច្នោះទេ អភិបាលកិច្ចមួយ ប្រាកដជានឹងក្លាយទៅជាការគ្រប់គ្រង

ដោយយកច្បាប់ជាខែល (Rule by law) ដែលច្បាប់ទាំងនោះ មិនបានគោរពទៅតាមគោលការណ៍សិទ្ធិមនុស្ស មិនបានអនុម័តស្របតាមដំណើរការតម្លាភាព និង ត្រូវបានអនុវត្តតាមទំនើងចិត្ត ឬដោយមានការរើសអើង។

ដូចដែលខ្ញុំបានថ្លែងនៅខាងដើម ច្បាប់ទាំងអស់ ត្រូវតែបានព្រាងឡើងដោយមានការប្រុងប្រយ័ត្ន ជាមួយនឹងការផ្សព្វផ្សាយសេចក្តីព្រាងនោះជាសាធារណៈ សម្រាប់ជាកម្មវត្ថុនៃការពិគ្រោះយោបល់ និងត្រូវបានត្រួតពិនិត្យឡើងវិញ ដើម្បីឲ្យស្របតាមបទដ្ឋានសិទ្ធិមនុស្សអន្តរជាតិ ដែលប្រទេសបានទទួលយកដោយស្ម័គ្រចិត្ត។ នៅក្នុងន័យនេះ ការអនុវត្តនៅបន្តមានភាពមិនស៊ីសង្វាក់គ្នានៅឡើយ។ ម៉្យាងទៀត ខ្ញុំត្រូវបានលើកទឹកចិត្ត ដោយដំណើរការព្រាងច្បាប់មួយ សម្រាប់សេចក្តីព្រាងច្បាប់ស្តីពីសិទ្ធិទទួលបានព័ត៌មាន ដែលខ្ញុំបានដឹងថា កន្លងមកសេចក្តីព្រាងច្បាប់នេះ គឺជាលទ្ធផលមួយនៃការពិគ្រោះយោបល់យ៉ាងទូលំទូលាយ។ ខ្ញុំក៏បានយល់ព្រមជាមួយនឹងសំណើមួយរបស់ក្រសួងយុត្តិធម៌ ក្នុងការចែករំលែកទស្សនៈរបស់ខ្ញុំស្តីពីសិទ្ធិមនុស្ស ដើម្បីឲ្យមានភាពស្របគ្នាជាមួយនឹងសេចក្តីព្រាងច្បាប់ស្តីពីការពពោះជំនួស។

ទោះជាយ៉ាងណាក៏ដោយ គួរឲ្យសោកស្តាយ ច្បាប់ទាំងឡាយ មិនត្រូវបានត្រួតពិនិត្យជាប្រព័ន្ធដោយអង្គនីតិបញ្ញត្តិ ទៅលើភាពសមស្របជាមួយសិទ្ធិមនុស្សនោះឡើយ។ ជាពិសេស ការយកចិត្តទុកដាក់ គឺត្រូវការជាចាំបាច់សម្រាប់ច្បាប់ទាំងឡាយដែលតាក់តែងក្នុងរបៀបរហ័ស (fast-tracked laws)។ ការធ្វើវិសោធនកម្មទៅលើរដ្ឋធម្មនុញ្ញ និងក្រមព្រហ្មទណ្ឌ ដែលត្រូវបានប្រកាសឲ្យប្រើប្រាស់កាលពីខែមុន មិនមានភាពសមស្របទៅតាមបទដ្ឋានអន្តរជាតិស្តីពីសេរីភាពក្នុងការបញ្ចេញមតិ និង ការរឹតត្បិតដែលត្រូវបានអនុញ្ញាតិនោះទេ។ ដូច្នេះ ច្បាប់ទាំងឡាយនៅកម្ពុជា មិនត្រូវបានអនុម័តស្របតាមប្រព័ន្ធតម្លាភាពដោយបើកចំហររបស់រដ្ឋាភិបាល ជានិច្ចនោះទេ។ **ខ្ញុំសូមថ្លែងឡើងវិញថា ច្បាប់ទាំងឡាយ ត្រូវតែបានត្រួតពិនិត្យឡើងវិញដោយមានការប្រុងប្រយ័ត្ន និងប្រកបដោយតម្លាភាព មុនពេលអនុម័ត ដើម្បីធានាបានភាពសមស្របជាមួយបទដ្ឋានសិទ្ធិមនុស្សអន្តរជាតិ។**

ដើម្បីធានាឲ្យមាននីតិរដ្ឋ ការអនុម័តច្បាប់ទាំងឡាយ ត្រូវតែអនុវត្តឲ្យមានភាពសមស្រប ក្នុងន័យសមភាពជាមូលដ្ឋាន និងស្របជាមួយភាពត្រឹមត្រូវនៃច្បាប់។ វាធ្វើឲ្យខ្ញុំកាន់តែមានភាពច្បាស់លាស់បន្ថែមទៀតថា វាមានភាពមិនស៊ីសង្វាក់គ្នាជាមួយនឹងការអនុវត្តច្បាប់ស្តីពីភ័ស្តុតាង។ មាត្រា៣២១ នៃក្រមនីតិវិធីព្រហ្មទណ្ឌ គឺជាបញ្ញត្តិគោល។ បច្ចុប្បន្ននេះ មិនមានសេចក្តីណែនាំបន្ថែមទៀតស្តីពីការវាយតម្លៃភ័ស្តុតាងទេ។ មានឧទាហរណ៍មួយចំនួនដែលចៅក្រមនៅសាលាឧទ្ធរណ៍ បានសម្រេចឲ្យជនជាប់ចោទរួចផុតពីបទចោទ ដោយហេតុផលខ្វះភ័ស្តុតាង ក៏ប៉ុន្តែការអនុវត្តជាក់ស្តែង គឺមិនមែនដូចករណីនេះទាំងអស់នោះទេ។ ការរំលាយគណបក្សសង្គ្រោះជាតិ និង ការបន្តការឃុំខ្លួនបណ្តោះអាសន្នអតីតប្រធានលោក កឹម សុខា គឺចោទជាបញ្ហា ដោយសារតែភ័ស្តុតាងដែលលើកឡើងសម្រាប់ការរំលាយគណបក្សសង្គ្រោះជាតិ គឺជាផ្នែកមួយនៃភស្តុតាងដូចគ្នា ដែលបច្ចុប្បន្នកំពុងត្រូវបានយកមកសំអាងដោយចៅក្រមស៊ើបសួរនៃសាលាដំបូង ដែលកំពុងតែដំណើរការនីតិវិធីស៊ើបអង្កេតថាតើត្រូវចោទប្រកាន់ប្រឆាំងនឹងលោក កឹម សុខា ចំពោះបទល្មើសសន្ទិដ្ឋិភាពជាមួយបរទេសឬយ៉ាងណា។ **ក្រសួងយុត្តិធម៌ គួរតែពិចារណាក្នុងការបង្កើតសេចក្តីណែនាំឲ្យបានច្បាស់លាស់ ស្តីពីបទដ្ឋានសមស្រប និង ការវាយតម្លៃលើភ័ស្តុតាង។ មេរៀនមួយចំនួនគួរតែត្រូវបានរៀនសូត្រពីការងាររបស់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា (អ.វ.ត.ក.)។**

ខ្ញុំសូមស្វាគមន៍យ៉ាងកក់ក្តៅចំពោះការងារនៅក្នុងសាលាឧទ្ធរណ៍ស្តីពីការពង្រឹងសំអាងហេតុតាមផ្លូវច្បាប់ និងការពិភាក្សារបស់យើងអំពីការបោះពុម្ពសាលដីកា។ ដើម្បីឲ្យការធ្វើសេចក្តីសម្រេចចិត្តក្នុងប្រព័ន្ធតុលាការ កាន់តែមានភាពល្អប្រសើរ និងមានតម្លាភាព គួរមានភាពច្បាស់លាស់ផ្នែកច្បាប់កាន់តែជាក់ច្បាស់ ការសម្រេចចិត្តគួរតែស្របទៅ

នឹងភ័ស្តុតាង និងការអនុវត្តច្បាប់ និងជាហេតុពង្រឹងការយល់ឃើញជាសាធារណៈនៅក្នុងឯករាជភាពនៃប្រព័ន្ធតុលាការ។ ជាការពិត ការបោះពុម្ព សាលក្រម/សាលដីកា និងសំអាងហេតុ ក៏នឹងផ្តល់អត្ថប្រយោជន៍ដល់សាកលវិទ្យាល័យ និងរាជបណ្ឌិតសភាវិជ្ជាជីវៈតុលាការផងដែរ នៅក្នុងការងារដ៏សំខាន់របស់ពួកគេ លើការអប់រំអ្នកជំនាញផ្នែកច្បាប់នាពេលអនាគត។ **ផែនការក្នុងការបោះពុម្ពផ្សាយសេចក្តីសម្រេច និងសំអាងហេតុផ្លូវច្បាប់ គួរតែត្រូវបានអនុវត្តបន្តទៅមុខទៀត។**

ការទទួលបានយុត្តិធម៌នៅតែត្រូវបានបដិសេធចំពោះមនុស្សជាច្រើន។ ខ្ញុំនៅតែមានកង្វល់ចំពោះការរីករាលដាលនៃការឃុំខ្លួនបណ្តោះអាសន្ន។ ខ្ញុំក៏មានកង្វល់ផងដែរ ចំពោះការអនុវត្តនៃសវនាការដែលមិនត្រូវបានធ្វើឡើងក្នុងរយៈពេលសមហេតុផល។ ខ្ញុំអំពាវនាវជាថ្មីម្តងទៀតសូមឲ្យទំលាក់បទចោទជាស្ថាពរ ចំពោះការចោទប្រកាន់ប្រឆាំងនឹងបុគ្គលិកនៅអង្គការអាដហុក។ វាគឺជាការរំលោភទៅលើសិទ្ធិទទួលបានការជំនុំជម្រះដោយមិនពន្យារពេលក្នុងករណីដែលមានការព្យួរបទចោទប្រកាន់ដោយមិនកំណត់ពេល ហើយនិងក្នុងករណីលើកយកការចោទប្រកាន់មួយចំនួនចោះៗមកជំនុំជម្រះជាថ្មី។ ឧទាហរណ៍ករណីលេចធ្លោរមួយចំនួន រួមមានករណីអ្នកស្រី ទេព វន្នី (២០១៣) និងលោក ញឹក ប៊ុនឆៃ (២០០៧)។ ការជំនុំជម្រះដោយយុត្តិធម៌ត្រូវតែធ្វើឡើងក្នុងរយៈពេលសមហេតុផល គិតពីថ្ងៃចាប់ខ្លួនដំបូង។ នេះគឺជាករណីកង្វល់ខ្លាំងជាពិសេសនៅពេលដែលមានមនុស្សត្រូវបានឃុំខ្លួនបណ្តោះអាសន្ន តាមការអនុវត្តជាស្តង់ដារនៅប្រទេសកម្ពុជា។

ខ្ញុំសូមស្វាគមន៍ការបង្កើតគោលនយោបាយថ្នាក់ជាតិស្តីពីជំនួយផ្នែកច្បាប់ និងជម្រុញឲ្យគម្រោងនេះ ត្រូវបានអភិវឌ្ឍយ៉ាងពេញលេញ និងមានធនធានគ្រប់គ្រាន់។ ខ្ញុំសូមបញ្ជាក់ជាថ្មីនូវការអំពាវនាវរបស់ខ្ញុំចំពោះប្រាក់ប្រដាប់ក្តីទាំងអស់ ត្រូវដាក់បង្ហាញជាសាធារណៈ។ ខ្ញុំគាំទ្រផងដែរ ការបន្តពិនិត្យឡើងវិញនូវច្បាប់គោលទាំងបីស្តីពីប្រព័ន្ធតុលាការ និងផែនការបណ្តុះបណ្តាលយ៉ាងពេញលេញ ហើយបន្ទាប់មកបញ្ជូនថៅក្រមនៃសាលាឧទ្ធរណ៍ទៅបំរើការនៅសាលាឧទ្ធរណ៍តាមតំបន់។ ទាំងនេះនឹងធ្វើឲ្យប្រព័ន្ធយុត្តិធម៌កាន់តែអាចទទួលយកបាន និងកាត់បន្ថយការភាពចាំបាច់ដែលអ្នកជាប់ឃុំជាច្រើននាក់ត្រូវធ្វើដំណើរមកកាន់រាជធានីភ្នំពេញ ដើម្បីចូលរួមក្នុងសវនាការសាលាឧទ្ធរណ៍។ **ខ្ញុំសូមអំពាវនាវដល់ក្រសួងយុត្តិធម៌ សូមជម្រុញឲ្យដំណើរការនូវមជ្ឈមណ្ឌលសេវាកម្មយុត្តិធម៌ក្នុងតំបន់ និងកម្មវិធីអប់រំដែលពាក់ព័ន្ធ ដើម្បីគាំទ្រការប្រើប្រាស់ឲ្យបានទូលំទូលាយអំពីការដាក់ឲ្យស្ថិតក្រោមការត្រួតពិនិត្យតាមផ្លូវតុលាការ (ជាជាងការឃុំខ្លួនបណ្តោះអាសន្ន (និងដើម្បីបំពេញនូវជម្រើសទោសផ្សេងៗជំនួសឲ្យការផ្តន្ទាទោសដាក់ពន្ធនាគារ។**

ក្នុងអំឡុងទស្សនកិច្ចនេះ ខ្ញុំបានទទួលរបាយការណ៍អំពីការបាញ់ប្រហារ នៅថ្ងៃទី៨ ខែមីនា ដោយកម្លាំងប្រដាប់អាវុធទៅលើអ្នកតវ៉ាទាក់ទងនឹងទំនាស់ដីធ្លីជាមួយក្រុមហ៊ុនចំការកៅស៊ូក្នុងស្រុកស្នួល ខេត្តក្រចេះ។ ខ្ញុំបានតាមដានស្ថានភាពនេះយ៉ាងជិតដិតបំផុត និងបានលើកឡើងនូវកង្វល់នានាអំពីបញ្ហានេះដោយផ្ទាល់នៅពេលជួបប្រជុំជាមួយមន្ត្រីនានារបស់រដ្ឋាភិបាល។ ខ្ញុំមានសេចក្តីព្រួយបារម្ភចំពោះព័ត៌មានដែលខ្ញុំទទួលបានដែលថាផ្ទះនិងទ្រព្យសម្បត្តិនៃសហគមន៍ដែលតវ៉ានេះ ត្រូវបានដុតបំផ្លាញ និងថាមានប្រជាពលរដ្ឋយ៉ាងតិចបីនាក់បានរងរបួសដោយសារការបាញ់គ្រាប់កាំភ្លើង និងការវាយដំ ដែលត្រូវបានអះអាងថាត្រូវបានប្រព្រឹត្តដោយកម្លាំងចម្រុះ។ ខណៈដែលខ្ញុំមានអារម្មណ៍ធូរស្រាលដែលហាក់មិនមានការរកឃើញណាមួយអំពីករណីស្លាប់នោះ ខ្ញុំសោកស្តាយដែលអ្នកសង្កេតការណ៍មកពីការិយាល័យ OHCHR និង អង្គការសង្គមស៊ីវិល ត្រូវបានហាមឃាត់មិនឱ្យចូលទៅកាន់តំបន់នោះ ដើម្បីបញ្ជាក់ឱ្យបានច្បាស់លាស់អំពីហេតុការណ៍ដែលបានកើតឡើង។ ដើម្បីជាប្រយោជន៍នៃការលើកកម្ពស់ជំនឿចិត្ត និងតម្លាភាព ខ្ញុំជឿជាក់ថា ការអនុញ្ញាតិឲ្យអ្នកសង្កេតការណ៍ឯករាជ្យចូលទៅកាន់តំបន់នោះ ជាការសំខាន់ណាស់។ **ខ្ញុំអំពាវនាវឲ្យមានការស៊ើបអង្កេតដោយឯករាជ្យ។**

ស្ថានភាពរឹករវក្នុងករណីនេះក្នុងខេត្តក្រចេះ បញ្ជាក់ពីភាពសំខាន់នៃការយល់ដឹង និងការឆ្លើយតបចំពោះមូលហេតុដែលជាឫសគល់នាំឲ្យមានការតវ៉ានេះ។ មូលហេតុដែលជាឫសគល់ទាំងនេះ ដែលតែងតែទាក់ទងនឹងការបដិសេធសិទ្ធិមនុស្ស ត្រូវតែមានការដោះស្រាយដោយលក្ខណៈត្រឹមត្រូវ ប្រសិនបើ សន្តិភាព ស្ថេរភាព និងការអភិវឌ្ឍន៍ត្រូវរក្សាបានដោយចីរភាព។

ក្នុងកិច្ចប្រជុំផ្លូវការនានារបស់ខ្ញុំ ខ្ញុំបានសម្តែងនូវកង្វល់ចំពោះភាពទូទៅនៃអត្ថាធិប្បាយនានាដែលផ្តោតតែលើអាទិភាពនៃសន្តិភាព ស្ថេរភាព និងការអភិវឌ្ឍន៍ ជាជាងការអត្ថាធិប្បាយពីសិទ្ធិមនុស្ស។ **អាស្រ័យហេតុនេះ ខ្ញុំសូមបញ្ជាក់ជាថ្មីថា សិទ្ធិមនុស្សគឺសំខាន់ចាំបាច់ខ្លាំងណាស់សម្រាប់សន្តិភាព ស្ថេរភាព និងការអភិវឌ្ឍន៍ដ៏ស្ថិតស្ថេរជានិរន្ត៍។ សិទ្ធិមនុស្សមិនអាចត្រូវបានគោរពដោយអន្លើៗ ឬមើលរំលងនោះទេ ហើយសិទ្ធិមនុស្សក៏មិនត្រូវលះបង់ឡើយ។ សន្តិភាពដែលខ្វះយុត្តិធម៌ គឺមិនស្ថិតស្ថេរទេ ហើយការអភិវឌ្ឍដែលខ្វះសេរីភាព គឺជាការបោះបង់ប្រជាជនចោល។** ទស្សនវិស័យនេះគឺផ្អែកលើធម្មនុញ្ញសហប្រជាជាតិ និង មាននៅក្នុងរបៀបវារៈឆ្នាំ ២០៣០ ដែលគូសបញ្ជាក់ពីគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាព។ ទស្សនវិស័យនេះក៏មានឆ្លុះបញ្ចាំងក្នុងរដ្ឋធម្មនុញ្ញរបស់កម្ពុជាដែលចែងថា ប្រទេសកម្ពុជានឹងត្រូវកសាងឱ្យទៅជា "កោះសន្តិភាព" ដោយផ្អែកលើប្រព័ន្ធប្រជាធិបតេយ្យសេរីពហុបក្ស ធានាសិទ្ធិមនុស្ស គោរពច្បាប់ ឱ្យបានឈានឡើងរីកចម្រើនលូតលាស់សំបូររុងរឿង។

**ចប់**

***សាស្ត្រាចារ្យ រ៉ូណា ស្មីត*** *(ចក្រភពអង់គ្លេស) ត្រូវបានក្រុមប្រឹក្សាសិទ្ធិមនុស្ស អ.ស.ប តែងតាំងជាអ្នករាយការណ៍ពិសេសស្តីពីស្ថានភាពសិទ្ធិមនុស្សនៅកម្ពុជា ក្នុងខែមីនា ឆ្នាំ២០១៥ ។*

*អ្នករាយការណ៍ពិសេស ពួកគាត់គឺជាផ្នែកមួយនៃអ្វីដែលគេស្គាល់ថាជានីតិវិធីពិសេសរបស់ក្រុមប្រឹក្សាសិទ្ធិមនុស្ស។ នីតិវិធីពិសេស (ស្ថាប័នដ៏ធំបំផុតមួយនៃអ្នកជំនាញឯករាជ្យនៅក្នុងប្រព័ន្ធសិទ្ធិមនុស្ស អ.ស.ប) គឺជាឈ្មោះទូទៅមួយនៃយន្តការឃ្លាំមើល និងស្វែងរកការពិតឯករាជ្យរបស់ក្រុមប្រឹក្សានេះ។ អ្នកកាន់អាណត្តិនីតិវិធីពិសេស គឺជាអ្នកជំនាញឯករាជ្យ ដែលក្រុមប្រឹក្សាសិទ្ធិមនុស្សបានតែងតាំងឡើង ដើម្បីធ្វើការងារពាក់ព័ន្ធនឹងស្ថានភាពសិទ្ធិមនុស្សរបស់ប្រទេសមួយជាក់លាក់ ឬបញ្ហាសិទ្ធិមនុស្សតាមវិស័យនីមួយៗ នៅគ្រប់តំបន់ទាំងអស់នៃពិភពលោក។ ពួកគាត់មិនមែនជាបុគ្គលិក អ.ស.ប ទេ ហើយធ្វើការឯករាជ្យពីរដ្ឋាភិបាល និង អ.ស.ប។ ពួកគាត់បំរើការក្នុងសមត្ថភាពបុគ្គលផ្ទាល់របស់ខ្លួន ហើយមិនទទួលប្រាក់បៀវត្សរ៍លើការងារនេះឡើយ។*

*ពិនិត្យមើលរបាយការណ៍របស់អ្នករាយការណ៍ពិសេសស្តីពីប្រទេសកម្ពុជា។*

*សិទ្ធិមនុស្ស អ.ស.ប គេហទំព័រសម្រាប់ប្រទេស៖ កម្ពុជា*

*សម្រាប់ព័ត៌មានបន្ថែម និងការសាកសួរព័ត៌មានផ្សេងៗ សូមទាក់ទង៖*
*លោក ម៉ាស៍មូដ ហ្គារហ្គា (Mahmoud Garga) តាមរយៈទូរស័ព្ទលេខ៖ (+៨៥៥ (0)១២ ៧៩០ ១៧៨ ឬ អ៊ីម៉ែល mgarga@ohchr.org )*

*អ្នកស្រី អ៊ីស្ទើរ ឡាំ (Esther Lam) តាមរយៈទូរស័ព្ទលេខ៖ (+៤១ ៧៩ ៤៤៤ ៣៩៤០ ឬ អ៊ីម៉ែល mgarga@ohchr.org )*

*សម្រាប់**ការសាកសួរព័ត៌មាន**ពាក់ព័ន្ធនឹងអ្នកជំនាញឯករាជ្យដទៃទៀតរបស់ អ.ស.ប សូមទាក់ទង៖*
*លោក ហ្សេរ៉ឺមី ឡូរង់ស៍ (Jeremy Laurence) សិទ្ធិមនុស្ស អ.ស.ប– អង្គភាពប្រព័ន្ធផ្សព្វផ្សាយ តាមរយៈទូរស័ព្ទលេខ៖*
*(+៤១ ២២ ៩១៧ ៩៣៨៣ ឬ អ៊ីម៉ែល jlaurence@ohchr.org)*

*ឆ្នាំ២០១៨ នេះ គឺជា**ខួបលើកទី៧០ នៃសេចក្តីប្រកាសជាសកលស្តីពីសិទ្ធិមនុស្ស** ដែលអង្គការសហប្រជាជាតិបាន អនុម័តនៅថ្ងៃទី១០ ខែធ្នូ ឆ្នាំ១៩៤៨។ សេចក្តីប្រកាសជាសកលនេះជាប់លំដាប់ថ្នាក់ពិភពលោក ផ្នែកខាងអត្ថបទដែល ត្រូវបានបកប្រែជា ៥០០ ភាសា ដោយផ្អែកលើគោលការណ៍គ្រឹះដែលថា «មនុស្សគ្រប់រូបកើតមកមានសេរីភាព និង សមភាពខាងសេចក្តីថ្លៃថ្នូរនិងសិទ្ធិ»។ គោលការណ៍គ្រឹះនេះ ស្ថិតនៅជាមួយមនុស្សគ្រប់រូប ជារៀងរាល់ថ្ងៃ។ ដើម្បី គោរពខួបលើកទី៧០ នៃឯកសារដែលមានឥទ្ធិពលដ៏វិសេសវិសាលនេះ និងដើម្បីរក្សាគោលការណ៍នេះកុំឲ្យបាត់បង់ យើងសូមស្នើឲ្យមនុស្សគ្រប់រូបនៅលើពិភពលោក **ក្រោកឈរឡើងដើម្បីសិទ្ធិមនុស្ស៖** www.standup4humanrights.org.*